# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/ ០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

## សម្រេច

មាត្រា ១-

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិចំណុះអគ្គនាយកដ្ឋានរដ្ឋបាល-កិច្ចការទូទៅ នៃក្រសួងទំនាក់ទំនងជាមួយ

រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បំពេញបន្ថែមឱ្យ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ២.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយ(០១)រូប និងអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ៣.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានភារកិច្ច ៖

-សម្របសម្រួល និង ទំនាក់ទំនងការងារជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ និង ទីភ្នាក់ងារផ្តល់ជំនួយដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ការងារគ្រប់វិស័យរបស់ក្រសួង

-សម្របសម្រួល និង ទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-រៀបចំពិធីការសម្រាប់ថ្នាក់ដឹកនាំ កិច្ចប្រជុំនានា និងពិធីផ្សេងៗ របស់ក្រសួងជាមួយភ្ញៀវបរទេស

-សម្រួលលិខិតស្នាមដូចជា លិខិតឆ្លងដែន ទិដ្ឋាការ របស់មន្ត្រីរាជការក្រោមឱវាទក្រសួងដែលត្រូវទៅបំពេញបេសកកម្មនៅក្រៅប្រទេសតាមការចាត់តាំងរបស់ក្រសួង និងជំនាញការបរទេស ដែលបំពេញការងារជាមួយក្រសួង

-ទទួលបន្ទុកកិច្ចការអាស៊ាន

-រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយអន្តរជាតិទៅលើវិស័យដែលពាក់ព័ន្ធជាមួយក្រសួងតាមគោលការណ៍ របស់រាជរដ្ឋាភិបាល

-រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិ សម្រាប់ចរចា និង ចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ

-តាមដាន និងវាយតម្លៃលើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យការបរទេស ដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃសហប្រតិបត្តិការអន្តរជាតិ

-បូកសរុប វាយតម្លៃរាល់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ដែលបានចុះពិធីសារ ជាមួយក្រសួង ហើយរាយការណ៍ពីលទ្ធផល នៃការងារទាំងនោះ ដោយសុំមតិកែសម្រួល ឬសុំបញ្ចប់កិច្ចព្រមព្រៀងណា ដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍កំណត់ ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធានមួយ ( ០១ ) រូប និង អនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ៤-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ម៉ែន សំអន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ